**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ០១៨ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពីការផ្ទេរអចលនវត្ថុ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញលិខិតលេខ ៥៥៩៧ សហវ.ទរ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញកំណត់ហេតុដេញថ្លៃ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៣
- បានឃើញសាលាកប័ត្របង្វែរ ឬ បង់ប្រាក់ចូលថវិការដ្ឋលេខ ០១/២០០៤ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៤

## សំរេច

**ប្រការ ១** : ផ្ទេរការគ្រប់គ្រងដី , រោង និង ម៉ាស៊ីនកិនស្រូវ លេខ យ៩ ដែលមានទំហំដី ២២ ម x ១៦ ម ស្ថិតនៅភូមិដង្កោ ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង ជូនទៅលោក វ៉ាំង វ៉ាត បន្ទាប់ពីដេញថ្លៃបានជាអ្នកគ្រប់គ្រងវិញ ដោយផ្តាច់ចេញពីបញ្ជីសារពើភ័ណ្ឌរបស់មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ។

**ប្រការ ២** : នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ , មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបងត្រូវ រៀបចំជិះបញ្ជី អចលនទ្រព្យទៅតាមបែបបទ ដែលរដ្ឋបានកំណត់ ។

**ប្រការ ៣** : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ , អគ្គាធិការ , នាយកខុទ្ទកាល័យ , នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ , មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង និងសាម៉ីខ្លួន មានភារកិច្ចរៀង១ខ្លួន អនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>**ចំលងជូន**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- សាលាខេត្តបាត់ដំបង
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម-ប្រសិទ្ធ**